# ចែករំលែកចំណេះដឹងនៃបទពិសោធន៍

# SHARE EXPERIENCE KNOWLEDGE

**ការវិភាគកំសាន្ត**

**(Informal Analysis)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : ពេលព្រានព្រៃជួបខ្លាដោយចៃដន្យ

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២១ មេសា ២០១២

វិភាគកំសាន្ត ដោយ (Informal analysis shared by) : លោក សៀង ប៊ូហឿង

## ១. សេចក្តីផ្តើម (Introduction)



-ឃើញខ្លាដើរ ព្រានព្រៃរត់គេចភ្លាម ។

-ឃើញខ្លាឈរ ព្រានព្រៃមិនហ៊ានចូលជិត ។

-ឃើញខ្លាងាប់ ព្រានព្រៃដើរចូល ។

-ឃើញខ្លាក្រាប ព្រានព្រៃមិនដឹងថាវាងាប់ ឬកំពុងសង្ងំ ។ មិនដឹងសម្រេចចិត្តយ៉ាងម៉េចទេ!

**២. ការយល់ដឹង (Knowledge)**

មុននឹងធ្វើការវិភាគចំនុចនីមួយៗខាងលើ ខ្ញុំសូមបញ្ជាក់អំពីការយល់ឃើញរបស់ខ្ញុំចំពោះការលើកឡើងខាងលើនេះថាក្នុងសាច់រឿងនេះ សត្វខ្លាតំណាងអោយអ្នកខ្លាំងពូកែដែលមានអំណាច ខណៈពេលដែលព្រានព្រៃតំណាងអោយជនឈ្លាតឱកាសក្នុងការវាយប្រហារ ដោយមិនអាចនិយាយបានទេថាមួយណាអាក្រក់ មួយណាល្អ។

## -ឃើញខ្លាដើរ ព្រានព្រៃរត់គេចភ្លាម ។

ត្រង់ចំនុចនេះ ខ្ញុំសូមធ្វើការវិភាគថា : អ្នកខ្លាំពូកែនៅពេលដែលបានធ្វើការតទល់ដោយសំដៅមករកអ្នកដែលមានបំណងចង់ធ្វើការវាយប្រហារខ្លួន អ្នកចង់ប្រហារនោះនឹងដកថយ ឬរត់គេចទាំងភ័យក្លាចជាមិនខាន។

## -ឃើញខ្លាឈរ ព្រានព្រៃមិនហ៊ានចូលជិត ។

ត្រង់ចំនុចនេះ ខ្ញុំសូមធ្វើការវិភាគថា : អ្នកខ្លាំងពូកែទោះជាមិនបានធ្វើការតទល់ជាមួយអ្នកចង់ប្រហារក៏ដោយ អោយតែបានដឹងខ្លួន ឬបានត្រៀមខ្លួនរួចជាស្រេចចំពោះរាល់ការវាយប្រហារទាំងឡាយណាដែលសំដៅមកលើខ្លួន អ្នកដែលចង់វាយប្រហារនោះនឹងមិនហ៊ានចូលមកក្បែរ ឬបើកការវាយប្រហារឡើយ។

## -ឃើញខ្លាងាប់ ព្រានព្រៃដើរចូល ។

ត្រង់ចំនុចនេះ ខ្ញុំសូមធ្វើការវិភាគថា : នៅពេលអស់អំណាច ឬមិនដឹងខ្លួនទាល់តែសសំចំពោះទង្វើអ្នកដទៃដែលចង់វាយប្រហារខ្លួន អ្នកខ្លាំពូកែនឹងប្រៀបដូចជាខ្លាងាប់មួយក្បាលអញ្ចឹង។

## -ឃើញខ្លាក្រាប ព្រានព្រៃមិនដឹងថាវាងាប់ ឬកំពុងសង្ងំ ។ មិនដឹងសម្រេចចិត្តយ៉ាងម៉េចទេ!

ត្រង់ចំនុចនេះ ខ្ញុំសូមធ្វើការវិភាគថា : ជាធម្មតា នៅពេលដែលអ្នកខ្លាំងមិនបញ្ចេញសកម្មភាពណាមួយដែលគួរអោយកត់សំគាល់ នោះអ្នកមានបំណងចង់ប្រហារ នឹងពិតជាមានការពិបាកក្នុងការកំណត់ពីស្ថានភាព ឬផែនការរបស់អ្នកខ្លាំងនោះ។ ចំពោះចំណុចនេះ អ្នកប្រហារនោះនឹងមិនហ៊ានបើកការវាយប្រហារ ហើយថែមទាំងបង្កើនការប្រុងប្រយត្ន័ ឬមួយក៏ធ្វើការវាយប្រហារដោយប្រថុយប្រថាន និងមិនច្បាស់លាស់ ជាមួយនឹងភាពប្រុងប្រយត្ន័កម្រិតខ្ពស់។

**៣. ការផ្តល់អនុសាសន៏ (Recommendation)**

ការវិភាគខាងលើ គឺគ្រាន់តែជាការវិភាគក្រៅផ្លូវការណ៏ផ្ទាល់ខ្លួនរបស់ខ្ញុំបាទតែប៉ុណ្ណោះ។ ប៉ុន្តែ ខ្ញុំសង្ឃឹមថាវាអាចមានប្រយោជន៏ ដល់អ្នកអាន ក្នុងការអភិវឌ្ឍសមត្ថភាពបន្ថែមផ្នែកស្មារតី ។